**សាកលវិទ្យាល័យភូមិន្ទកសិកម្ម**

**មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម**



# ដំណាំលម្មើ

## Date Palm




ណែនាំដោយបណ្ឌិត៖ ឃួន អៀង

រៀបរៀងដោយ៖ លឹម សេងហួរ

ជំនាន់ទី ៣៤



ឆ្នាំសិក្សា៖ ២០១៩-២០២០

# មាតិកា


១.លក្ខណៈទូទៅ..........................................................................................................១

២.លក្ខណៈរូបសាស្ត្រ.......................................................................................................៤

៣.ពូជ.....................................................................................................................១១

៤.លក្ខខណ្ឌដី ..........................................................................................................១២

៥.អាកាសធាតុ .........................................................................................................១២

៦.បច្ចេកទេសដាំដុះ ...................................................................................................១២

៧.ការដាំដុះ ...............................................................................................................១៦

៨.ការថែទាំ.................................................................................................................១៦

៩.ការប្រមូលផល........................................................................................................២០

១០.ការស្តុកទុក...........................................................................................................២២

១១.ការកែច្នៃ.............................................................................................................២៤

១២.ឯកសារយោង .......................................................................................................

## ១.លក្ខណៈទូទៅ

| | | |
|---|---|---|
| សណ្ឋាន | ៖ | Arecaceae |
| ឈ្មោះវិទ្យាសាស្ត្រ | ៖ | *Phoenix dactylifera* |
| អំបូរ | ៖ | Phoenix |
| ប្រភេទ | ៖ | dactylifera |
| ឈ្មោះជាភាសាអង់គ្លេស | ៖ | Date Palm |
| ដើមកំណើត | ៖ | អេហ្ស៊ីប និង មេសូប៉ូតាមៀ |



# អត្ថប្រយោជន៍

មកទល់នាពេលនេះប្រជាជនខ្មែរភាគច្រើនសុទ្ធតែស្គាល់ដំណាំលម្មី និងធ្លាប់បានទទួលទានផ្លែលម្មីទុំហើយ។ ប៉ុន្តែប្រហែលជាមិនបានចាប់អារម្មណ៍ដឹងអំពីអត្ថប្រយោជន៍ល្អៗមិនគួរឲ្យជឿរបស់ផ្លែឈើនេះ ចំពោះសុខភាពរាងកាយនៅឡើយទេ។ តាមពិតទៅលម្មីមិនត្រឹមតែមានរសជាតិឆ្ងាញ់ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាប្រភេទផ្លែឈើម្យ៉ាងដែលសម្បូរទៅដោយសារធាតុចិញ្ចឹមចាំបាច់ផងដែរ មានទាំង វីតាមីន ជាតិសសៃ ព្រមទាំងសារធាតុប្រឆាំងអុកស៊ីតកម្មដែលអាច ជួយព្យាបាលប្រយុទ្ធប្រឆាំងទប់ស្កាត់បញ្ហាសុខភាពផ្សេងៗបានផងដែរ។ តាមគេហទំព័រសុខភាពមួយ ដែលមានឈ្មោះថា Health.com.kh បានបង្ហាញពីអត្ថប្រយោជន៍គួរឲ្យភ្ញាក់ផ្អើលនៃការទទួលទានផ្លែលម្មីចំពោះសុខភាពរាងកាយដូចតទៅ។[1]

❖ **បំបាត់ និងទប់ស្កាត់បញ្ហាទល់លាមក**

ដឹងទេថា គ្រាន់តែទទួលទានលម្មីចំនួនតែ ៣ ផ្លែក្នុងមួយថ្ងៃជាប្រចាំនោះ បញ្ហានៃការទល់លាមកគ្រប់ប្រភេទ និងសូម្បីតែទល់លាមករ៉ាំរ៉ៃ ក៏នឹងត្រូវបានកាត់បន្ថយផង ដែរ។ នេះក៏ព្រោះតែផ្លែលម្មីសម្បូរទៅដោយជាតិសសៃដែលជួយធ្វើអោយពោះវៀនដំណើរការបានស្រួល ហើយសកម្មជាងមុនប្រឆាំងនឹងបញ្ហាទល់លាមក និងថែមទាំងអាចកម្ចាត់ជាតិពុលផ្សេងៗចេញពីរាងកាយក៏ដូចជា ធ្វើអោយក្រពះមានសុខភាពល្អប្រសើរឡើងទៀតផង។

❖ **ល្អសម្រាប់សុខភាពបេះដូង**

លម្មី គឺជាប្រភពដ៏ល្អនៃសារធាតុប្រឆាំអុកស៊ីតកម្ម និងជាតិសសៃដែលចាំបាច់សម្រាប់សុខភាពបេះដូង រួមទាំងសសៃឈាមបេះដូង ដោយវាជួយសម្អាតនិងបើកសសៃឈាមដែលកកស្ទះ។ លម្មីថែមទាំងមានផ្ទុកសមាសធាតុ Isoflavones ដែលមានអត្ថប្រយោន៍បំផុត ជួយក្នុងការព្យាបាលទប់ស្កាត់បញ្ហានៃជំងឺបេះដូង និងរក្សាសុខភាពល្អប្រសើរនៃបេះដូង។

[1] https://www.health.com.kh/archives/31078

- **ជួយគ្រប់គ្រងកម្រិតកូឡេស្តេរ៉ូល**

លម្មើ គឺមានផ្ទុកបរិមាណខ្ពស់នៃវីតាមីន B និងវីតាមីន K ក៏ដូចជាជាតិដែក និងប៉ូតាស្យូម។ ដូច្នេះប្រសិនបើអ្នកទទួលទានលម្មើចំនួនត្រឹមតែ ៣ ផ្លែក្នុងមួយថ្ងៃជាប្រចាំនោះអ្នកនឹងគ្មានថ្ងៃជួបប្រទះបញ្ហានៃការកើនឡើង នៃកម្រិតកូឡេស្តេរ៉ូលមិនល្អឡើយ។ ឬប្រសិនបើអ្នកកំពុងជួបប្រទះបញ្ហានៃកូឡេស្តេរ៉ូលនោះ ក៏ផ្លែលម្មើអាចជួយគ្រប់គ្រងកម្រិតត្រឹមត្រូវរបស់វាមិនអោយបង្ករផលប៉ះពាល់ណាមួយដល់សុខភាពបានឡើយ។

- **ពង្រឹងសុខភាពឆ្អឹង**

លម្មើ គឺជាប្រភពនៃជាតិសេលេញ៉ូម, ទង់ដែង, ម៉ាញ៉េស្យូម និងវីតាមីន K ព្រមទាំងសារធាតុផ្សេងៗជាច្រើនទៀតដែលល្អសម្រាប់សុខភាពឆ្អឹងរឹងមាំ។

- **ជួយគ្រប់គ្រងកម្រិតសម្ពាធឈាម**

លម្មើ ក៏មានផ្ទុកនូវជាតិរ៉ែ និងសារធាតុអុកស៊ីតកម្មប៉ុន្មានប្រភេទដូចជា ប៉ូតាស្យូម ជាដើម ដែលល្អសម្រាប់សម្ពាធឈាម។ ប្រសិនបើអ្នកទទួលទានលម្មើចំនួន ៣គ្រាប់ក្នុងមួយថ្ងៃជាប្រចាំនោះបញ្ហាផ្សេងៗដែលពាក់ព័ន្ធ ជាមួយសម្ពាធឈាមនឹងគ្មានថ្ងៃកើតឡើងចំពោះអ្នកឡើយ។ ជាតិម៉ាញ៉េស្យូម និងប៉ូតាស្យូម ជួយគ្រប់គ្រងជាតិសូដ្យូម និងសម្រួលសរសៃឈាម ហើយថែមទាំងធ្វើអោយកម្រិតនៃសម្ពាធឈាមលក្ខណៈប្រសើរឡើងផងដែរ។

## សមាសភាពផ្សំក្នុងផ្លែលម្មើចំនួន ១០០ ក្រាម[2]

| សមាសភាពផ្សំ | | ចំនួន |
|---|---|---|
| ថាមពល | គ.កាល់ឡូរី | ២៨២ |
| កាបូនអ៊ីដ្រាត | ក្រាម | ៧៥.០៣ |
| ខ្លាញ់ | ក្រាម | ០.៣៩ |
| ប្រូតេអ៊ីន | ក្រាម | ២.៤៥ |
| វីតាមីន (A) | IU | ១០ |
| វីតាមីន ($B_3$) | មីលីក្រាម | ១.២៧៤ |
| វីតាមីន ($B_6$) | មីលីក្រាម | ០.១៦៥ |
| សារធាតុរ៉ែ (K) | មីលីក្រាម | ៦៥៦ |
| សារធាតុរ៉ែ (Ca) | មីលីក្រាម | ៣៩ |
| សារធាតុរ៉ែ (Fe, Iron) | មីលីក្រាម | ១.០២ |
| ជាតិទឹក | ក្រាម | ២០.៥៣ |

## ២.លក្ខណៈរូបសាស្ត្រ

➢ **ដើម(Trunk)**

តួដើមឬក៏ផ្នែកឆ្នូតនៃដើមលម្មើគឺតែមួយ មានរាងជាស៊ីឡាំងបញ្ឈរដែលមានអង្កត់ផ្ចិតស្មើគ្នា (ជាមធ្យមគឺ១ម៉ែត្រ) តែពេញមួយវដ្តជីវិតរបស់វាអាចលូតបានប្រវែងរហូតដល់ទៅ ៣០ម៉ែត្រ(Zaid and de Wet 2002)។ ដើមវាគ្របដណ្តប់ដោយគល់ធាងដែលបាំងជាតិសរសៃនៅខាងក្នុង វាជាយន្តការរវិវត្តមួយដើម្បីការពារដើមអោយគេចផុតពី តិណាស៊ី សត្វល្អិត និង សត្វផ្សេងៗទៀត ហើយក៏វាដើរតួរនាទីយ៉ាងល្អប្រៀបបាននិងអ៊ីសូឡង់កាត់បន្ថយការបាត់ជាតិទឹក។ ទឹកហើយនឹងសារធាតុចិញ្ចឹមត្រូវបានផ្លាស់ប្តូរ តាមរយៈជាលិកាសរសៃនាំ(Vascular Tissue) ដែលផ្សំឡើងពីបាច់សសៃនាំយ៉ាងតឹងណែន។ នៅខាងចុងដើមមានដុះពន្លក(phyllophor or phyllogen) ហើយនឹងតាមចំហៀងៗ Fascicular cambium។

[2] https://fdc.nal.usda.gov/fdc-app.html#/food-details/171726/nutrients







- **ស្លឹក (Leave)**

ស្លឹកលម្អើត្រូវបានគេហៅថាធាង គឺតម្រៀបជាលក្ខណៈឆ្លាស់គ្នា ស្លឹកព័ទ្ធជុំវិញដើមឡើងដូចជាឫស័រ (Uhl and Dransfield 1987)។ ស្លឹកដែលពេញវ័យ គឺមានប្រវែង ៤ ម៉ែត្រ ប៉ុន្តែស្លឹកមានប្រវែងពី ៣ ទៅ ៦ ម៉ែត្រ និង ទទឹង ០.៥ម នៅធាងកណ្តាល វ៉ែនស្លឹកដែលតូចឆ្ពោះទៅចុងស្លឹកទាំងពីរ (Zaid and de Wet 2002)។ ស្លឹកលម្អើបែងចែកបានជាបីតំបន់គឺៈ




តំបន់ធាង តំបន់ឆ្អឹងខ្នង(Spinal) ដែលផ្លាស់ប្តូរទៅជាតំបន់ផ្ទៃស្លឹក(Blade) ដែលពេលគេកាន់ធាងឃើញថាមានទំរង់ជាធរណីមាត្រ។ មុំកូនស្លឹកគឺត្រូវបានបែងចែកនៅក្នុងតំបន់ផ្ទៃស្លឹក។ ចំនួនស្លឹកដែលផលិតបានប្រចាំឆ្នាំប្រែប្រួលពី ១០ ទៅ ២៦ស្លឹក ហើយដើមលម្អើដែលពេញ

វ័យប្រែប្រួលប្រហែលពី ១០០ ទៅ ១២៥ ស្លឹក។ ៥០% នៃស្លឹកគឺអ្នកសកម្មខាងសំយោគ (Zaid and de Wet 2002)។ ស្លឹកដែលនៅជាប់នឹងដើម នៅពេលដែលវាចាស់ទៅ ត្រូវកាត់ចេញដោយដៃ។ ស្លឹកដែលនៅជាប់ផ្កាត្រូវបានហៅថា spathe ព័ទ្ធជុំវិញកញ្ចុំផ្កាមិនទាន់ពេញវ័យ។

- **ឫស (Roots)**

លម្អើមានប្រព័ន្ធឫសស្វែរដែលមានប្រភពចេញពីគល់នៅបាតនៃដើមរបស់វា។ ឫសដំបូងមានប្រវែងជាមធ្យម ៤ ម៉ែត្រ និងអាចលាតសន្ធឹងរហូតដល់ ១០ ម៉ែត្រនៅក្នុងដីដែលមានពន្លឺគ្រប់គ្រាន់។ ឫសដំបូងបានធ្វើអោយឫសទី២កើតឡើងនិងបន្ថែមសាខាជាឫសទី៣ទៀតដែលមានប្រវែងនិងអង្កត់ផ្ចិតខ្លីជាងមុន(Zaid and de Wet 2002)។ ឫសដំបូងមានប្រភពចេញមកពីគ្រាប់ប៉ុន្តែក៏បន្តលូតលាស់ផងដែរប្រសិនជាដើមលម្អើ គឺលូតលាស់ចេញពីផ្នែកលូតលាស់ណាមួយ (Off Shoot) ឬជាលិកាវប្បកម្មគ្រាប់គ្រាប់ (Tissue-cultured seedling)។ វាជាពពួករុក្ខជាតិមូណូកូទីលេដូន ដើមលម្អើមិនមានឫសកែវទេ។ ប្រព័ន្ធឫសរបស់វាគឺជាឫសស្វៃហើយឫសគឺមានរាងជាសសៃស្រដៀងទៅនិងដំណាំពោត។ ឫសទី២របស់វាលេចឡើងនៅលើឫសដំបូងដែលវិវត្តដោយផ្ទាល់ពីគ្រាប់។ ឫសទី២ទាំងនោះផលិតជាឫសចំហៀង(ឫសទី៣និងបន្តបន្ទាប់ទៀត) នៃប្រភេទឫសដែលមានអង្កត់ផ្ចិតនិងប្រវែងទាំងប្រមាណដូចៗគ្នា។

គ្រប់ឫសលម្អើទាំងអស់មានវត្តមានឫសដង្ហើម(Pneumatics) ដែលជាសរីរាង្គជំនួយការដកដង្ហើម។ ឫសរបស់វាត្រូវបានគេរកឃើញថាមានចម្ងាយឆ្ងាយជាង ៦ម៉ែត្រចេញពីដើមហើយនិងមានជម្រៅជ្រៅជាង ៦ ម៉ែត្រ។ ប៉ុន្តែ ៨៥ភាគរយនៃឫសទាំងនោះគឺបានចាក់ចូលទៅក្នុងតំបន់ដែលមានជម្រៅ ២ម៉ែត្រ ដោយចាក់២ម៉ែត្រជុំវិញលម្អើនៅក្នុងជម្រៅដីល្បាយ (Munier, 1973)។ ឫសរបស់ដើមលម្អើត្រូវបានគេបែងចែកជា ៤ តំបន់គឺ៖

- **តំបន់ទី១** គេហៅថាតំបន់ជំនួយដល់ដំណាកដង្ហើម(Respiratory Zone)៖ ជាផ្នែកដែលនៅព័ទ្ធគល់លម្អើមានជម្រៅមិនលើសពី ២៥ស.ម ហើយដុះចាក់ទៅខាងៗឆ្ងាយបំផុតមិនលើសពី០.៥ម៉ែត្រចេញពីដើមគ្មានសរសៃនាំ(Stipe)។

- **តំបន់ទី២** គេហៅថាតំបន់សារធាតុចិញ្ចឹម(Nutritional Zone)៖ វាជាតំបន់ដ៏ធំមួយ ហើយមានសមាមាត្រខ្ពស់បំផុតនៃឫសចម្បងនិងឫសបន្ទាប់បន្សំ។ វាអាចមានឫស ចំនួន ១០០០ក្នុងដី១ម $^{២}$(Oihabi, 1991)។
- **តំបន់ទី៣** គេហៅថាតំបន់ការស្រូបយក(Absorbing Zone)៖ សារៈសំខាន់នៃតំបន់ នេះគឺអាស្រ័យលើប្រភេទវប្បកម្មហើយនិងជម្រៅនៃទឹកក្រោមដី។ ជាធម្មតាវាត្រូវបាន គេរកឃើញនៅជម្រៅពី១.៥ ទៅ ១.៨ម៉ែត្រ។ ភាគច្រើនឫសចម្បងដែលមានដង់ស៊ីតេ ថយចុះពីចំណុចខ្ពស់មកចំណុចទាបត្រូវបានគេរកឃើញនៅទីនេះ។ ដង់ស៊ីតេឫសនៃ តំបន់នេះគឺទាបជាងនៅតំបន់ទី២ មានប្រហែលតែ២០០ឫសក្នុងផ្ទៃដី១ម $^{២}$ ប៉ុណ្ណោះ។
- **តំបន់ទី៤** ភាគច្រើននៃតំបន់នេះពឹងផ្អែកលើទឹកក្រោមដី។ នៅសណ្ឋានដីដែលមាន ទឹកក្រោមដីរាក់ៗ វាពិបាកបែងចែករវាងតំបន់ ៣ និង ៤ណាស់។ ដោយសារតែឫស ទាំងពីរត្រូវបានគេរកឃើញនៅទីនេះ។ នៅពេលទឹកក្រោមដីជ្រៅ ឫសនៃតំបន់នេះ ចាក់ចុះកាន់តែជ្រៅ។

➢ **ផ្កា(Flower)**

ដើមលម្អើគឺជាពពួករុក្ខជាតិឯកភេទ កន្លែងដែលផ្កាញី និងផ្កាឈ្មោលចេញគឺនៅលើ ដើមពីរផ្សេងគ្នា (Uhl and Dransfield 1987)។ ផ្កាញី និងផ្កាឈ្មោលត្រូវបានរក្សាទុកនៅផ្អោប ភ្ជាប់ទៅនឹងធាងមានទម្រង់ជាកញ្ចុំផ្កា (Inflorescence)មួយ ដែលហៅថាចង្កោមផ្កា មានរាងចបជីក(Spadix) រហែកតាមបណ្តោយ នៅតំណាក់កាលផ្ការីក(Anthesis) ដែលអនុញ្ញា អោយលម្អងនៃផ្កាឈ្មោលផ្កាញីទុំ។



➤ **ផ្លែ(Fruit)**

ផ្លែនៃដើមលម្មើត្រូវបានគេហៅថាលម្មើ(Date) វិវត្តចេញមកពីការបង្ករកំណើតអូវុលមួយនៅក្នុងកេសរញី ខណៈអូវុលពីរផ្សេងទៀតត្រូវបានពន្លូតចោល ប៉ុន្តែនៅតែអាចមើលឃើញឡើងវិញនៅត្របកផ្លែ។ ប្រសិនបើគ្មានការបង្ករកំណើតលិចឡើង បីឬក៏ច្រើនជាងនេះនៃកញ្ចុំកេសរញីនិងលូតលាស់ដំណាលគ្នា។ ផ្លែលម្មើវិវត្តនៅលើចង្កោមផ្កា ហើយមានលក្ខណៈជាប៊ែរីដោយមានភ្នាសបណ្តូលព័ទ្ធជុំវិញគ្រាប់។ បម្រែបម្រួលដ៏ធំមាននៅក្នុងរូបរាង ទំហំ ពណ៌ ហើយនិងសមាសធាតុគីមីនៃផ្លែលម្មើ (Zaid and de Wet 2002; Al-Yahyai and Kharusi 2011), អាស្រ័យភាគច្រើនលើពូជខុសៗគ្នា ប៉ុន្តែក៏នៅលើអាកាសធាតុ ដី ហើយនិងលក្ខណលូតលាស់ផងដែរ។ ស្រដៀងគ្នាដែរ គ្រាប់លម្មើមានទំហំនិងរូបរាងផ្សេងៗគ្នា ប៉ុន្តែជាទូទៅពួកវាមានរាងជាជ្រលងនៅត្រង់ពោះ ពងក្រពើ ហើយមានទំហំចាប់ពី ៥ ទៅ ១៥មីលីម៉ែត្រ មានអំប្រីយ៉ុងមួយកើតនៅចំកណ្តាលនៃគ្រាប់ ដែលព័ទ្ធជុំវិញដោយសាច់គ្រាប់ (Endosperm)។

បន្ទាប់ពីដំណើរលម្អង ហើយនិងការបង្ករកំណើត ផ្លែលម្មើលូតលាស់លូតលាស់តាមរយៈដំណាក់កាលវិវត្តខុសគ្នាចំនួន ៥ ដែលត្រូវបានកំណត់ដោយការផ្លាស់ប្តូររូបវន្ត និងគីមីនៅដំណាក់កាលនិមួយៗ។ ដំណាក់កាលទាំងនោះគឺ Hababouk, Kimri, Khalal, Rutab, and Tamar (Zaid and de Wet 2002)។




**Figure 3. The five growth stages of a date fruit by days post pollination (DPP) (Al-Mssallem et al., 2013).**

- **ដំណាក់កាល Hababouk** មានរយៈពេល ៤ ទៅ ៥ សប្តាហ៍បន្ទាប់ពីកំណត់ផ្លែ ហើយលក្ខណៈដែលសម្គាល់បានគឺអត្រាលូតលាស់យឺត។ ផ្លែមានរាងមូលហើយពណ៌គឺក្រែម(cream)ទៅបៃតងខ្ចី។
- **ដំណាក់កាល Kimri** មានរយៈពេលពី ៩ ទៅ ១៤ សប្តាហ៍ហើយនៅអំឡុងដំណាក់កាលនេះផ្លែវាចាប់ផ្តើមពន្លូត ហើយគ្រាប់វិវត្តឆាប់រហ័ស ហើយបង្កើនបរិមាណទំងន់ មាឌ និងកាត់បន្ថយជាតិស្ករ។ ផ្លែនៅដំណាក់កាល Kimri គឺមានពណ៌បៃតង ហើយត្រូវបានសម្គាល់ដោយកំហាប់តានីនខ្ពស់(Tannin concentration) ដែលវាត្រូវបានបន្ថយនៅពេលផ្លែលូតលាស់។
- **ដំណាក់កាល Khalal** ត្រូវបានគេស្គាល់ថាដូច Bisir គឺនៅពេលដែលផ្លែមានលក្ខណៈសរីរវិទ្យាពេញវ័យ ហើយផ្លាស់ប្តូរទៅជាពណ៌ជាក់លាក់ណាមួយ ជាធម្មតាផ្លាស់ប្តូរផ្សេងគ្នាបន្តិចម្តងៗអាចពីក្រហមហើយនិងលឿង។ ដំណាក់កាលនេះមានរយៈពេលពី ៣ ទៅ ៥ សប្តាហ៍ ហើយសញ្ញាវាបង្ហាញពីការលុតលាស់យឺត (3%-4%ការឡើងទំងន់គ្រាប់) និងការប្រមូលផ្តុំបន្ថែមទៀតនៃជាតិស្ករចំពោះផ្លែដែលមានទំហំ និងទំងន់ពេញលេញ។ ពូជភាគច្រើនដែលមានជាតិស្ករខ្ពស់អាចត្រូវបានគេប្រើទាំងស្រស់ និងឆ្អិននៅដំណាក់កាលនេះ។
- **ដំណាក់កាល Rutab** គឺនៅពេលដែលចុងផ្លែចាប់ផ្តើមទន់ហើយពណ៌ផ្លាស់ប្តូរទៅជាពណ៌ងងឹត។ លម្មើភាគច្រើនត្រូវបានប្រើប្រាស់ស្រស់នៅដំណាក់កាលនេះដែលមានរយៈពេលពី ២ ទៅ ៤ សប្តាហ៍។ ដោយសារភាពទន់របស់វា លម្មើនៅដំណាក់កាលនេះបាត់បង់បរិមាណទឹកជាមធ្យមពី ៣0% ទៅ ៤៥% ប៉ុន្តែស្ករនៅតែបន្តកកុញ។
- **ដំណាក់កាល Tamar** ពេលដែលផ្លែលម្មើទុំពេញលេញ ភាពទន់នៃផ្លែមានទាំងស្រុងតែម្តង។ ពណ៌ផ្លែលម្មើប្រែជាស្រអាប់ខ្មៅនៅដំណាក់កាលនេះ ដែលត្រូវបានសម្គាល់ដោយកម្រិតសំណើមទាបផងដែរ (១0% - ២៥%) និងកំហាប់ជាតិស្ករសរុបខ្ពស់។ ដំណាក់កាលនេះមានរយៈពេលពី ២ ទៅ ៤ សប្តាហ៍ ហើយលម្មើគឺសមស្របសម្រាប់ការរក្សាទុក ឬ កែច្នៃស្ងួតរយៈពេលវែង។




ដើមលម្មើចាប់ផ្ដើមចេញផ្លែនៅអាយុជាមធ្យម ៥ ឆ្នាំជាមួយនឹងការផ្ដល់ទិន្នផលជាមធ្យមពី ៤០០ ទៅ ៦០០ គីឡូក្រាម/ដើម/ឆ្នាំហើយបន្តផ្ដល់ទិន្នផលរហូតដល់ទៅ ៦០ ឆ្នាំ។[3]

- **គ្រាប់(Seed)**

ដូចគ្នាទៅនិងផ្លែដែរ គ្រាប់លក្ខណៈគ្រាប់ប្រែប្រួលទៅតាមប្រភេទពូជ លក្ខខណ្ឌបរិស្ថាននិងការលូតលាស់។ ទំងន់របស់គ្រាប់មួយអាចមានចាប់ពីតិចជាង ០.៥ក្រាម ទៅក្រោម ៤ក្រាម និងមានប្រវែងពី ១២ ទៅ ៣៦មីលីម៉ែត្រ និងមានទទឹងពី ៦ ទៅ ១៣មីលីម៉ែត្រ។ គ្រាប់ជាធម្មតាមានរាងទ្រវែង នៅត្រង់ពោះគ្រាប់មានចង្អូរ(Ventrally grooved) ជាមួយនិងអំប្រីយ៉ុងតូចមួយ ហើយនិងមានសាច់គ្រាប់រឹងដែលបានផ្សំឡើងពីសាច់ឈើនៅខាងក្នុងនៃជញ្ជាំងកោសិកា។ គ្រាប់លម្មើគឺត្រូវបានត្រាំហើយដាក់ធ្វើជាចំណីសត្វ។ ប្រេងរបស់វាគឺសមស្របសម្រាប់ប្រើក្នុងសាប៊ូ និងគ្រឿងសម្អាង។ គ្រាប់លម្មើមានផ្ទុកអាស៊ីត Lauric ០.៥៦ - ៥.៤%។ ពួកវាត្រូវបានគេកែច្នៃប្រភេទគីមីរបស់វាទៅជាអាស៊ីត Oxalic។[4]

[3] https://www.frontiersin.org/articles/10.3389/fpls.2017.00845/full
[4] https://www.feedipedia.org/node/687

## ៣.ពូជ(Variety)

ពូជលម្មើគេចែកចេញជា ៣ ប្រភេទគឺ៖ ពូជហូបផ្លែស្រស់ ពូជហូបផ្លែពាក់កណ្ដាលស្រស់ពាក់កណ្ដាលដំណាប់ និងហូបផ្លែដំណាប់។

ពូជហូបផ្លែស្រស់មាន ៣ ពូជបាហ៊ី(ផ្លែពណ៌លឿង) ពូជហាយ៉ានី(ផ្លែពណ៌លឿង) ពូជម៉ាសាបាស៊ី(ផ្លែពណ៌ក្រហម)។

| | ការពិពណ៌នាអំពីភាពទុំនៃផ្លែ |
|---|---|
| **Barhi** | ប្រើប្រាស់ស្រស់៖ នៅដំណាក់កាល Khalal, មានឱជារសផ្អែម ពណ៌លឿងអាចប្រើតែនៅក្នុងរដូវប្រមូលផលប៉ុណ្ណោះ |
| **Hayani** | ប្រើប្រាស់ស្រស់៖ មានពណ៌ខ្មៅចាំងចែង មានផ្លែវែងហើយមិនសូវផ្អែម |
| **Medjoul** | ផ្លែស្ងួត៖ មានផ្លែធំ ទន់ហើយផ្អែម មានពណ៌ពីត្នោតខ្ចីទៅត្នោតពេញវ័យ |
| **Amari** | ផ្លែស្ងួត៖ ទន់ ផ្អែម ហើយមានទំហំផ្លែល្មម |
| **Deglet Nour** | ផ្លែស្ងួត៖ មានរសជាតិពេញនិយមដោយសារពាក់កណ្ដាលទុំ មានពណ៌ត្នោតខ្ចីទៅពេញវ័យ |
| **Hadrawi** | ផ្លែស្ងួត៖ មានសាច់ផ្អែម ពណ៌ត្នោតក្រម៉ៅ |
| **Zahidi** | ផ្លែស្ងួត៖ មានទំហំមធ្យម ហើយមិនផ្អែមពេក និងមានពណ៌មាស |

តាមពិតទៅមានពូជចំនួនបីប្រភេទដែលទីពេញនិយមនៅលើទីផ្សារសកលគឺ៖

- Medjoul ៖ មានទំហំធំ និងរូបរាងទាក់ទាញ។
- Deglet Nour ៖ មានរសជាតិប្លែកហើយភាគច្រើនស្គាល់នៅមជ្ឈិមបូព៌ា។
- Barhi ៖ គេច្រើនទទួលទានវានៅដំណាក់កាល Khalal (ទុំតិចៗ)។

## ៤.លក្ខខណ្ឌដី

ដើមលម្មើលូតលាស់នៅលើដីប្រភេទផ្សេងៗគ្នា ប៉ុន្តែដីដែលផ្តល់ទិន្នផលល្អបំផុតគឺល្បាយខ្សាច់(Sandy Loam)។ ដំណាំលម្មើត្រូវបានគេចាត់ទុកថាមានភាពធន់ ទៅនិងដីដែលមានជាតិអំបិលខ្ពស់ បើប្រៀបធៀបទៅនិងដំណាំហូបផ្លែដទៃទៀត។ ហើយលក្ខខណ្ឌដីអាល់កាឡាំងដែលមាន pH រហូតដល់ ៨ ក៏ដំណាំលម្មើនៅតែអាចដុះលូតលាស់បានតែជាធម្មតាគេចាត់ទុកថា pH ល្អនៅចន្លោះពី ៦.៦ ទៅ ៧.៥ ។

## ៥.អាកាសធាតុ

**សំណើម៖** បន្ទាប់ពីដាំភ្លាមៗចូលស្រោចលម្មើរបស់អ្នកអោយបានជោគល្អដើម្បីកុំអោយមានខ្យល់ច្រើនពេកនៅក្នុងដី។ ចូរស្រោចទឹកជារៀងរាល់ថ្ងៃបន្ទាប់ពីដាំបាន២សប្តាហ៍ដើម្បីជួយអោយវាបង្កើនកំលាំង។ បន្ទាប់ពី២ខែមកចូលកាត់បន្ថយបរិមាណទឹកបន្តិចម្តងៗ ដោយគ្រាន់តែស្រោចស្រព២ដងក្នុង១សប្តាហ៍បានហើយ។ ការស្រូបយកទឹកប្រចាំថ្ងៃរបស់លម្មើពេញវ័យត្រូវបានគេប៉ាន់ប្រមាណថាមានពី ១៥០ ទៅ ២០០លីត្រ។ ដើម្បីធានានូវការរីវត្តនិងការលូតលាស់ល្អចាំបាច់ត្រូវការប្រព័ន្ធបន្សាចទឹក។ ទឹកភ្លៀងហើយនិងសំណើមនៃខ្យល់ មានជំងឺផ្សិត ហើយនិងរារាំងការបង្ករកំណើត។ ទឹកភ្លៀងនៅអំឡុងពេលផ្លែទុំចុងក្រោយអាចបណ្តាលអោយខូចលម្មើដែលកំពុងលូតលាស់ជាច្រើន។

**សីតុណ្ហភាព៖** តម្រូវការសីតុណ្ហភាពស្ងួត (ក្តៅហើយស្ងួត) ជាមួយនិងសីតុណ្ហភាពចន្លោះពី ២៥ ទៅ ៣២ អង្សាសេ ហើយនិងការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់។ ដើមលម្មើត្រូវការសីតុណ្ហភាព ១៨ អង្សាសេសម្រាប់ការចេញផ្កា (នៅក្នុងម្លប់) ហើយចំពោះការកំណត់ផ្លែសីតុណ្ហភាពលើសពី ២៥ អង្សាសេ។

## ៦.បច្ចេកទេសដាំដុះ

**ការបន្តពូជ ៖** ការបន្តពូជរបស់គ្រួសារលម្មើភាគច្រើនសុធតែតាមរយៈគ្រាប់ឧទាហរណ៍ដូង និងដូងប្រេង។ ប៉ុន្តែមានវិធីសាស្ត្របីយ៉ាងដើម្បីបន្តពូជលម្មើគឺបន្តពូជតាមរយៈគ្រាប់ ការបង្ករកំណើតតាមមែក(វិធីសាស្ត្រប្រពៃណី) ហើយនិងជាលិកាវប្បកម្មដែលទើបនិងបង្កើតថ្មី។[5]

**ការជ្រើសគ្រាប់ពូជ និងការបណ្តុះ**[6]

[5] BOOK → date_palms_organic_cultivation-guide (2.2. Seeds and seedlings)
[6] https://www.wikihow.com/Plant-Date-Seeds

- ចូរជ្រើសរើសគ្រាប់ចេញពីផ្លែដែលទុំល្អ មិនស្អុយ មានរសជាតិឆ្ងាញ់ បន្ទាប់មកយកគ្រាប់ចេញពីសាច់ផ្លែទៅដាក់លាងទឹកអោយជ្រះជាតិចេញដើម្បីកុំអោយមានរោគផ្សិត។ បើសិនជាលាងមិនជ្រះស្អាតទេអ្នកអាចត្រាំទឹកក្តៅចោល២៤ម៉ោងរួចលាងសម្អាតវាចេញហើយ។
- **ត្រាំគ្រាប់ក្នុងទឹកសាបរយៈពេល ៤៨ ម៉ោង៖** ចាក់ទឹកត្រជាក់ដាក់ចានឬពែងរួចត្រាំគ្រាប់ក្នុងនោះ។ ផ្លាស់ប្តូរទឹកមួយថ្ងៃម្តងដោយច្របាច់យកជាតិរំអិលចេញ ធ្វើបែបនេះជួយកុំអោយមានផ្សិតដុះ។
    - ការត្រាំគ្រាប់បែបនេះនិងធ្វើសំបកគ្រាប់ស្រូបយកទឹកហើយនិងរៀបចំសម្រាប់ដំណើរការដុះពន្លក។
    - ជ្រើសរើសគ្រាប់ណាដែលអណ្តែតទឹកបោះចោលនិងរើសយកមួយណាលិចមកដាំ







- **បត់គ្រាប់ចំនួន ២ ចូលទៅក្នុងក្រដាសជូតមាត់សើម៖** ចាក់ទឹកលើក្រដាសជូតមាត់ដើម្បីផ្សើមវា បន្ទាប់មកលាក្រដាសជូតមាត់អោយស្មើល្អដាក់គ្រាប់ចំនួន២គ្រាប់នៅខាងចុងក្រដាសរួចបត់វាចូលក្នុង ធ្វើយ៉ាងណាអោយក្រដាសនៅជុំវិញគ្រាប់។
- **ដាក់ក្រដាសជូតមាត់ដែលបត់គ្រាប់នោះចូលទៅក្នុងថង់ផ្លាស្ទិចហើយបិទវា**
- **ទុកដាក់ថង់ប្លាស្ទិចនោះនៅកន្លែងដែលមានសីតុណ្ហភាពអ៊ុនៗ ងងឹតចំនួនពី៧ទៅ៨សប្តាហ៍៖** គ្រាប់និងដុះពន្លកល្អនៅសីតុណ្ហភាពល្អបំផុតគឺចន្លោះពី ២១ទៅ២៤អង្សាសេ។ ចូរស្វែងរកកន្លែងណាដែលនៅផ្ទះរបស់មានសីតុណ្ហភាពល្មម។ ដូចជាផ្នែកខាងលើនៃទូទឹកកកឬក៏ប្រើកម្រាលអ៊ុនទៅគ្រប់គ្រងសីតុណ្ហភាពដោយបន្ថែមការប្រុងប្រយ័ត្នទៀត។

- **ចូរពិនិត្យមើលគ្រាប់អោយបានទៀងទាត់ខ្លាចមានដុះផ្សិត៖** រៀងរាល់២សប្តាហ៍ ចូរបើកមាត់ថង់មើលការលូតលាស់។ ចូរពិនិត្យមើលបើមានដុះផ្សិតត្រូវប្តូរក្រដាសថ្មីនិងផ្សើមទឹកវិញ។ បន្ទាប់ពី ២ទៅ៤សប្តាហ៍អ្នកគួរតែឃើញមានឫសតូចៗដុះចេញពីគ្រាប់ពូហើយ។
- **ការដាំគ្រាប់ពេលដុះពន្លក៖** ចូរបន្តពិនិត្យមើលការដុះពន្លកតើវាមានសភាពបែបណាហើយ។ នៅពេលគ្រាប់បានដុះពន្លកនិងឫសហើយវាជាពេលដើម្បីយកវាចេញទៅដាក់ដាំហើយ។
- **អ្នកអាចយកគ្រាប់ដែលដុះពន្លកនោះទៅដាក់ក្នុងផើងឬអ្វីផ្សេងទៀតដែលអ្នកចូលចិត្ត៖** ការដាំក្នុងផើងចូររៀបផើងដោយចាក់ដីកំប៉ុសនៅផ្នែកខាងក្រោម និងដាក់ដីខ្សាច់នៅខាងលើបន្តិច។ បន្ទាប់មកស្រោចទឹកវាអោយមានសំណើមល្មម រួចហើយដាក់គ្រាប់ដែលដុះពន្លកនោះ ដោយដាក់ផ្នែកឫសអោយចំដីកំប៉ុសហើយពោយដីខ្សាច់ពីលើបន្តិចហើយគ្របវាបន្តិចនិងដាក់វានៅកន្លែងណាដែលត្រូវពន្លឺព្រះអាទិត្យដោយប្រយោល ដែលមានសីតុណ្ហភាពនៅរង្វង់ ២១អង្សាសេ។
    - គ្រាប់គួរតែដុះពន្លកស្លឹកបន្ទាប់ពី ៣ ទៅ ៨ សប្តាហ៍




ការដាំដុះ (កាដាំគ្រាប់ដែលបានដុះពន្លក)

- **ចូររកផើងឬថង់ណាដែលមានរន្ធបង្ហូរទឹកច្រើននៅផ្នែកបាត**

- ចូរចាក់បំពេញផើងនោះជាមួយដីដែលមានជីរជាតិ៣ភាគ៥
- ចូរដាក់គ្រាប់ដែលបានដុះពន្លកនោះនៅចំកណ្តាលផើងឬថង់នៅជម្រៅ២.៥ស.ម
- លប់ដីអោយនៅត្រឹមពន្លករួចស្រោចទឹក

តាមប្រពៃណីចំការលម្មើនៅ Oasis ដង់ស៊ីតេនៃដើមគឺខ្ពស់ខ្លាំងដោយសារតែបែបនេះទើបកញ្ចុំស្លឹកបានបិទ។ ដង់ស៊ីតេខ្ពស់ផ្តល់នូវម្លប់និងការពារខ្យល់ដូចច្នោះវាបង្កើតជាបរិយាកាសមីក្រូដែលនាំអោយស្ថានភាពលំបាកនៃអាកាសធាតុក្តៅ ហើយសួតត្រូវបានទប់ដើម្បីធ្វើអោយស្ថានភាពរស់នៅមានស្ថេរភាពជាងមុន។ ទោះបីជាយ៉ាងណាក៏ដោយដង់ស៊ីតេខ្ពស់បន្ថយឱកាសសម្រាប់ការដាំដុះដំណាំបន្ទាប់បន្សំមួយចំនួន ចឹងហើយក៏ណែនាំអោយគ្រឿងយន្តធ្វើការដាំដុះដំណាំលម្មើ។

នៅក្នុងចម្ការឯកទេសប្រព័ន្ធដាំដុះទូទៅបំផុតនៅក្នុងក្រឡាផ្ទៃទំហំ ៩ម x ៩ម ឬ (១០មx១០ម) ដោយទុកអោយនៅចន្លោះសម្រាប់ការប្រើប្រាស់ម៉ាស៊ីន និងដាំដំណាំបន្ទាប់បន្សំផ្សេងទៀត។ ក្នុងករណីចម្ការពេញវ័យត្រូវការអោយមានភាពស្រស់បំព្រងឡើងវិញលម្មើក្មេងៗ ត្រូវបានដាំអោយជិតទៅនិងដើមលម្មើពេញវ័យៗដើម្បីដកពួកវាពេលដើមក្មេងៗចាប់ផ្តើមចេញផ្កាផ្លែ។ ពេលខ្លះដំណាំលម្មើត្រូវបានដាំនៅជុំវិញចម្ការដំណាំផ្សេងៗទៀត ឬដំណាំសាកវប្បកម្មជាមួយដើមឈើហូបផ្លែផ្សេងៗទៀត។

លម្មើក្មេងត្រូវបានដាំនៅក្នុងរណ្តៅ (៩០ស.ម$^3$) ដើម្បីដាក់ឫសវាអោយនៅជិតប្រព័ន្ធទឹកក្រោមដី(Water table)។ នៅក្នុងប្រព័ន្ធដាំដុះបែបប្រពៃណីដីអាល់កាឡាំងបានយកចេញនិងដាក់មកវិញនូវល្បាយនៃសារធាតុសរីរាង្គ ខ្សាច់ ហើយនិងផេះ។ នៅក្នុងប្រព័ន្ធដាំដុះសរីរាង្គវាត្រូវបានណែនាំឱ្យបន្ថែមសម្ភារៈសរីរាង្គដែលបានមកពីដីកំប៉ុសផងដែរ។

វាត្រូវបានផ្តល់ជាអនុសាសន៍ថាអោយរៀបចំអោយពេញលេញពី ២ ទៅ ៣ ខែមុនដាំ។ បន្ទាប់ពីដាំ លម្មើដែលនៅវ័យក្មេងត្រូវបានស្រោចទឹកជាប្រចាំថ្ងៃយ៉ាងហោចណាស់ ១ ទៅ ២ សប្តាហ៍។ ដើម្បីការពារដើមលម្មើទើបតែដាំទាំងនោះគួរតែព័ទ្ធរបងជុំវិញ និងកាត់ស្លឹកឈើ ចំបើង របស់ពុកផុយមួយចំនួនទៀតមកគ្របគល់។ ជាធម្មតាកសិករជ្រើសរើសរដូវដែលមានសីតុណ្ហភាពល្មមសម្រាប់ការដាំ។ ទោះបីជាយ៉ាងណាក៏ដោយ យើងអាចដាំលម្មើពេញមួយឆ្នាំអោយតែមានទឹកគ្រប់គ្រាន់។ ដើម្បីអោយមានការដំណើរលម្អងក្នុងធម្មជាតិ ដើមឈ្មោល ២ ទៅ ៣ ដើមត្រូវបានដាំជាមួយនិងដើមញី ១០០ ដើមដើម្បីបង្កើតផ្លែ។

មុនពេលការដាំដើមថ្មីមកដល់ចូលរៀបចំដីចម្ការដោយរៀបចំ កសាងប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធស្រោចស្រព។ ដើមដែលពេញវ័យៗគួរតែរំលំចោលប៉ុន្តែស្លឹកវាគួរតែកាត់ជាចំណែកតូចៗយកទៅដាក់ក្នុងដីដោយភ្ជួររាស់ពីលើ (ចូរដាក់តែស្លឹកឬមែកណាដែលគ្មានការបំផ្លាញពីសត្វល្អិតនិងជំងឺ)។ នៅតំបន់ខ្លះត្រូវបានគេណែនាំអោយអោយដាំដើម Tamarisk ជាខែលក្រវ៉ាត់(Tamarix aphylla) ហើយនិង Ironwood (Casuarina equisetifolia) មុនពេលដាំដើមលម្អើ។

## ៧.ការដាំដុះ (យុទ្ធសាស្ត្រពិពិធកម្ម៖ Diversification Stratergies)

ជាប្រពៃណីការធ្វើវប្បកម្មឆ្លាស់ជាមួយនិងដំណាំហូបផ្លែដទៃទៀត (citrus, pomegranates, olives, grapes, guava) ឬដីដែលអាចដាំដំណាំបានដូចជា (alfalfa, barley, beans etc.) ត្រូវបានអនុវត្តនៅក្នុងតំបន់ផលិតកម្មសំខាន់ៗជាច្រើន។ បើគ្មានម្លប់ដែលបានមកពីដំណាំលម្អើទេដំណាំដ៏ទៃទៀតជាញឹកញាប់មិនអាចលូតលាស់បានទេ។ ការដាំដុះបែបសរីរាង្គមិនអនុញ្ញាតឱ្យមានប្រព័ន្ធឯកវប្បកម្មទេ។ ជាពិសេសការធ្វើអន្តរកម្មជាមួយពពួកសណ្តែកអាល់ហ្វាហ្វា និងពពួកឡេហ្គុម(Legumes) បានផ្តល់នូវការធ្វើអោយប្រសើរឡើងនៃដីជាមួយនិងអាសូតក៏ដូចជាចំណីសត្វសម្រាប់ផលិតកម្មបសុសត្វ។ បន្ថែមទៅលើទីកន្លែងដែលសមស្របសម្រាប់ប្រព័ន្ធដាំដុះចំរុះនៃដំណាំលម្អើ ដីដែលអាចដាំដំណាំ (Arable crops) ហើយនិងឈើហូបផ្លែ ចម្ការដំណាំលម្អើធំៗគួរតែបិទបាំង/ព័ទ្ធជុំវិញដោយរបងបៃតង(ឧទាហរណ៍ ដាំជាមួយ Polynesian Ironwood (Casuarina ssp.) ឬដោយ stripes of Spanish Reed (Arundo donax) នៅក្នុងចម្ការ។ ទាំងពីរនេះគឺជារុក្ខជាតិដែលប្រើច្រើននៅក្នុងអាកាសធាតុស្ងួត។

## ៨.ការថែទាំ

**ការស្រោចស្រព ៖** ជាមធ្យមដំណាំលម្អើប្រើប្រាស់ទឹកប្រចាំថ្ងៃ ១៨៤.៤លីត្រ/ថ្ងៃសម្រាប់គ្រប់ដំបន់ទាំងអស់។ ការប្រើប្រាស់ទឹកនៃដំណាំលម្អើមានអត្រាចន្លោះពី ៥៩.៤ និង ៨០ម៉ែត្រ$^{៣}$/ដើម។ ការស្រោចស្រពគឺជាកម្មវិធីដ៏ទាន់ពេលមួយនៃការស្រោចទឹមចំពោះដំណាំដែលត្រូវការទឹក។ ទឹកខ្លះដែលបានស្រោចទៅនៅពេលមិនចាំបាច់ វាដូចការខ្ជះខ្ជាយរបស់ដ៏មានតម្លៃមួយ។ ឧទាហរណ៍៖ បើសិនជាយើងស្រោចទឹកយឺតពេកនៅរដូវមួយ យើងទៅស្រោចនៅរដូវបន្ទាប់វាគ្មានប្រយោជន៍ទេព្រោះដំណាំវាបានងាប់បាត់ហើយ ឬក៏ផលិតកម្មទទួលរងផលប៉ះពាល់យ៉ាងខ្លាំងដោយធ្វើអោយវាគ្មានផ្លែ បើទោះបីជាអ្នកផ្តល់ទឹកនៅដំណាក់កាលលូតលាស់ក៏ដោយក៏វាគ្មានប្រយោជន៍ ដែរ។ ការពិតដែលផ្ទុយពីនេះគឺ ប្រសិនជាដាក់ទឹកច្រើនពេកក៏ដំណាំប្រហែលជារងផលប៉ះពាល់ផងដែរ។ ដំណាំអាច

ងាប់ដោយសារតែលិចទឹក។ ជាធម្មតាដំណាំលម្មើមិនទទួលរងគ្រោះពេលមានទឹកច្រើនលើសទេ។ ការស្រោចស្រពត្រូវធ្វើឡើងនៅកន្លែងដែលឫសដំណាំងាយស្រួលចាក់ទៅដល់។ វានឹងគ្មានប្រយោជន៍ទេប្រសិនជាទៅស្រោចនៅកន្លែងដែលឫសចាក់ទៅមិនដល់។

ចូរយើងក្រឡេកទៅមើលការវិវត្តឫសនៃដំណាំលម្មើ។ ប្រសិនេជាដីត្រូវបានបែងចែកជាបួនស្រទាប់នៃជម្រៅស្មើៗគ្នាចាប់តាំងពីកំពូលដល់បាត ៤០%នៃឫសទាំងអស់អាចត្រូវបានរកឃើញនៅក្នុងស្រទាប់ខាលលើ ៣០%នៅក្នុងស្រទាប់ទី២ ២០%នៅក្នុងស្រទាប់ទី៣ និងស្រទាប់ចុងក្រោយនៅសល់តែ១០%ប៉ុណ្ណោះ ភាគរយដាក់ដូចគ្នានៅជុំវិញដំណាំដូចក្នុងរូប។ ភាគរយនៃទឹកនិងដកយកចេញពីដីដូចគ្នាក្នុងស្រទាប់ខុសៗគ្នាដោយសារតែវត្តមាននៃឫសក្នុងស្រទាប់និមួយៗ។

ចំពោះដំណាំលម្មើពេញវ័យមានឫសចាក់ក្រោម៥ម៉ែត្រ និងចំហៀងជុំវិញដើម៣ម៉ែត្រ។ ដូច្នេះវាមើលឃើញថាចំពោះដំណាំលម្មើ ៤០%នៃចំនួនទឹកទាំងអស់គឺបាកស្រក់ចុះចេញពី៥០ស.មដំបូង ៧០%ទៀតចេញពី១០០ស.មដំបូង ៩០%ទៀតចេញពី១៥០ស.មដំបូង និងមានតែ១០%ប៉ុណ្ណោះចេញពីស្រទាប់ចុងក្រោយ ឬ១៥០ ទៅ ២០០ ស.ម ឬជ្រៅជាងនេះ។ ចំពោះរុក្ខជាតិក្មេងៗដែលជាកូនរុក្ខជាតិជម្រៅនេះអាចប្រែប្រួលពី ២៥ ទៅ ៥០ ស.ម ហើយឫសជុំវិញពី ១០ ទៅ ៣០ ស.ម អាស្រ័យទៅលើទំហំនៃរុក្ខជាតិនោះ។ នេះមានន័យថាការស្រោចស្រពទឹកត្រូវតែធ្វើឡើងទៅតាមចម្ងាយនៃឫសរុក្ខជាតិដែលបានចាក់ទៅដល់។

នៅអារ៉ាប់ប៊ីសាអូឌីការប៉ាន់ប្រមាណអំពីតម្រូវការទឹករបស់ដំណាំលម្មើត្រូវបានរាយការ៍ដោយអ្នកស្រាវជ្រាវជាច្រើន។ការប៉ាន់ស្មានទាំងនេះខុសគ្នារវាងពី ៦២០០ ទៅ ៥៥០០០ម$^{៣}$/ហិចតា។ អាលាស្បា៉ (Alazaba,2001) ត្រូវបានគេប៉ាន់ប្រមាណថាតម្រូវការទឹកមានចន្លោះពី ១៥០០០ ទៅ ៥៥០០០ម$^{៣}$/ហិចតា អាស្រ័យលើប្រព័ន្ធស្រោចស្រព ឬប្រព័ន្ធលេចជ្រាប។ ការប៉ាន់ប្រមាណការប្រើប្រាស់ទឹកជាក់ស្តែងមានអាត្រាចន្លោះពី ២១៣៦០ ទៅ ២៨២៩០ ម$^{៣}$/ហិចតា ចំពោះដង់ស៊ីតេ ១០០ ដើម/ហិចតា (Al-Amoud et al.,2012)។ ថ្មីៗនេះលោក **Dewidar et al. (**2015) បានប៉ាន់ប្រមាណតម្រូវការទឹកនៃដំណាំលម្មើ ដោយប្រើ non-weighing lysimeter។ ពួកគេបានរាយការណ៍ថាដែលខ្នាតវ៉ាស់ចំណុះតម្រូវការទឹកសម្រាប់ដំណាំលម្មើធ្លាក់ចុះចន្លោះពី ៨៧ ទៅ ២៩៧លីត្រ/ថ្ងៃ ជាមួយនិងតម្រូវការប្រចាំថ្ងៃជាមធ្យម ១៨២លីត្រ។

## ការដាក់ជី

តម្រូវការជីអសីរាង្គក្នុងមួយដើមគឺ អាសូត(N)៥០០ក្រាម, ផូស្វ័រ(P)៣០០ក្រាម, ប៉ូតាស្យូម(K)២៥០ក្រាម។ សម្រាប់ដំណាំសរីរាង្គគេតែងប្រើប្រាស់យុទ្ធសាស្ត្របង្កើនសារធាតុសរីរាង្គក្នុងដីដោយផ្អែកទៅលើការដាក់ជីស្រស់ និងជីកំប៉ុស។ យុទ្ធសាស្ត្រទាំងនេះជាវិធីបុរមបុរាណដែលគេតែងតែប្រើ។ ជីលាមកសត្វត្រូវបានគេដាក់ដោយជីករាងជារង្វង់ជុំវិញដើមដើម្បីកប់លាមកទាំងនោះ។ ចំណែកឯសារធាតុអាសូតវិញ ត្រូវបានគេផ្តល់អោយតាមរយៈដំណាំឆ្លាស់គ្នា នៃសណ្តែកAlfafa (ពពួករុក្ខជាតិស្ថិតក្នុងអំបូរ Legum) ជារៀងរាល់៤ឆ្នាំម្តងគេតែតែបន្ថែមជីកំប៉ុស ដោយសារតែជីកំប៉ុសមិនត្រឹមតែផ្តល់ជីប៉ុណ្ណោះទេតែថែមទាំងជាអ្នករក្សាទឹកបានល្អផងដែរ។

## សត្វល្អិត

- **Cottony cushion scale**៖ Parlatoria blanchardii and Phoenicoccus marlatti ត្រូវបានរីករាលដាលយ៉ាងទូលំទូលាយ។ វាធ្វើការជញ្ជក់លើស្លឹកនាំអោយស្លឹកឆាប់ងាប់។ **Cottony cushion scale** ពួកត្រូវការសំណើមនិងកន្លែងដែលគ្មានខ្យល់ ពេលមានអាសកាសធាតុបែបនេះវានិងមកនៅក្នុងចម្ការបាន។ ការគ្រប់គ្រងជីវសាស្ត្រត្រូវបានធ្វើឡើង ជាមួយនិងប្រដាក់ទ័រធម្មជាតិដូចជាពពួកស្រឹងប្រភេទ Pharascymnus, Cybocephalus and Chilocorus bipustulatus ប៉ុន្តែវិធីសាស្ត្រដាំដុះក៏ត្រូវតែសមស្របផងដែរ។
- **Bryobia**៖ Oligonychus afrasiaticus and Paratetranychus simplex ត្រូវបានរីករាលដាលយ៉ាងទូលំទូលាយនៅទ្វីបអាហ្វ្រិកខាងជើងនិងនៅមជ្ឈឹមបូព៌ា និងអូពីរ៉ាសស៊ីសក្នុងរដ្ឋកាលីហ្វ័រញ៉ា។ **Bryobia** ជ្រៀតចូលក្នុងស្លឹកនិងផ្លែមិនទាន់ទុំ ពួកវាត្រូវការលក្ខខណ្ឌស្ងួតនិងខ្យល់។ ការប្រើ Arundo donax ក្នុងដាំចម្រុះគឺវាធ្វើអោយរីករាលដាលកាន់តែខ្លាំងដូច្នេះត្រូវដំណាំចម្រុះផ្សេងទៀត។
- **Caterpillars (ដង្កូវមេអំបៅ)**៖ ទូទៅបំផុតនោះជាដង្កូវនៃមេអំបៅ Ephestia cautella and Batrachedra amydraula ដែលវាស៊ីស្លឹកនិងជ្រៀតចូលក្នុងផ្លែ។ Bacillus Thuringiensis ត្រូវបានគេប្រើសម្រាប់គ្រប់គ្រងជីវសាស្ត្រ។
- **Bugs (**ពពួកស្រឹង)៖ ស្រឹង Rhinoceros នៃប្រភេទ Oryctes spp។ ពួកវាស៊ីជាលិកានៃស្លឹកខ្ចីៗហើយបំផ្លាញផ្នែកខ្លះនៃរុក្ខជាតិ។ មានលទ្ធភាពផ្សេងៗគ្នានៃការគ្រប់គ្រងជីវសាស្ត្រ៖ ដកយកចេញនូវកន្លែងរីករាលដាលរបស់វាដូចជាអ្វីៗដែលរលួយបានមកពីរុក្ខជាតិ និងជីស្រស់។ រៀប

ចមអន្ទាក់នៃពោងបណ្តុះកូនសម្រាប់ចាប់ភ្នាក់ងារជីវសាស្ត្រដោយពពួកផ្សិត Metarrhizium anisopliae និង វីរុស Rhabdionvirus oryctes។

- **Fruit bugs** (ស្រឹងទិចផ្លែ) នៃប្រភេទ Cotinis texana, Carpophilus hemipterus, Coccotrypes dactyliperda ពួកវាបំផ្លាញផ្លែទុំហើយនិងកញ្ចុំផ្កា។ កញ្ចុំផ្កាត្រូវបានរុំព័ទ្ធឡើងដោយស្រឹងហើយវារក្សាកញ្ចុំផ្កានោះទុក។



Cottony cushion scale


Bryobia


Caterpillars



Bugs



Fruit bugs

## ៩.កាប្រមូលផល

**ការប្រមូលផលដោយដៃ(Manual Harvesting)**

កាលពីមុនឧបករណ៍ដែលត្រូវបានប្រើ សម្រាប់ការប្រមូលផលលម្មើគឺ កណ្ដៀវមួយប៉ុណ្ណោះ ដែលវាមានលក្ខណៈសាមញ្ញ ប៉ុន្តែគ្រោះថ្នាក់ និងមិនស្រួលក្នុងការកាន់ហើយគុណភាពទាប។ ឧបករណ៍នេះមានលក្ខណៈសាមញ្ញ ដោយរៀបចំឡើងពីក្រណាត់ចងក្រវ៉ាត់នឹងចង្កេះប្រអោបឡើងដើមលម្មើតែម្ដង តែវាអាចមានគ្រោះថ្នាក់ព្រោះអាចមានភាពចៃដន្យនៅពេលណាមួយចំពោះអ្នកដែលទៅបេះនៅខាងចុងដើមលម្មើ អាចធ្លាក់ពីដើមបើភ្លាត់។

លម្មើត្រូវបានប្រមូលផលដោយកាត់ចង្កោមនៅពេលតែមួយ។ អ្នកបេះត្រូវឡើងដើម ឬប្រើជណ្ដើរឡើងទៅប្រមូលផ្លែ ហើយមិនមែនក្នុងចង្កោមមួយផ្លែទាំងអស់វាទុំដំណាលគ្នាទេ ចឹងហើយក្នុងមួយដើមៗត្រូវឡើងបេះ៨ ដងរយៈពេលពី២ទៅ៣ខែទើបអស់។



**ការប្រមូលផលដោយគ្រឿងយន្ត(Mechanical Harvesting)**

ប្រភេទមេកានិចក្នុងការប្រមូលផលលម្មើជាប្រព័ន្ធគ្រឿងយន្ត ដែលបំពាក់ដោយដៃវែងៗដែលនៅខាងចុងនៃដៃគ្រឿងយន្តមានរាងជាកន្ត្រក ដែលអាចអោយមនុស្សឈរនៅក្នុងនោះដើម្បីបេះផ្លែបាន(Mazloumzadeha et al., 2008)។ អាស្រ័យលើប្រភេទពូជ និងអាកាសធាតុដែលអាចត្រូវជ្រើសរើសតាមវិធីមួយក្នុងចំណោមខាងក្រោម៖

1. ការកាត់មែកត្រូវបានធ្វើឡើងនៅចង្កោមផ្លែណាដែលទុំដំណាលគ្នាល្អ
2. ការគោះមែកត្រូវបានធ្វើឡើងនៅចង្កោមផ្លែណាដែលទុំមិនស្មើគ្នា
3. ការជ្រើសដោយដៃត្រូវបានធ្វើឡើងចំពោះពូជដែលមានគុណភាពខ្ពស់ ផ្លែវាថ្លៃដែលងាយខូចពេលប៉ះពាលរំញ័រ។




ការអភិវឌ្ឍម៉ាស៊ីនរំញ័រដើមលម្អើទៅប្រមូលផល បានចាប់ផ្តើមឡើងជាច្រើនទសវត្សមកហើយ (Perkins and Brown, 1967; Levin et al., 1969; Brown et al., 1983; Sarig, 1989)។ គ្រឿងមាស៊ីន ដែលបានស្នើរឡើងក៏ ស្ថិតក្នុងតម្លៃសមរម្យ ផងដែរ (Ali and Akyurt, 1998)។ ម៉ាស៊ីនដែលសមរម្យអាចជួយបង្កើនផលិតភាពរបស់កសិករជនជាតិដើមភាគតិច ហេតុនេះហើយគុណភាពនៃផលិផលមានភាពទាន់ពេលវេលាបានល្អប្រសើរ និងមានភាពកខ្វក់តិចតួច ហើយអាចមានសុវត្ថិភាពជាងការឡើងដើមលម្អើដោយដៃ ឬប្រខ្សែក្រវ៉ាត់ចង្កេះ ពីមុន(Al-Suhaibani et al., 1988)។

Al-Suhaibani et al. (1992) បានរចនានិងវាយតម្លៃសេវាកម្មម៉ាស៊ីនបេះលម្អើដែលបានប្រើដីជាជំនួយ។ Shamsi (1998) បានអភិវឌ្ឍនិងសាកល្បងនូវម៉ាស៊ីនដែលបំរើសេវាកម្មឡើងបេះលម្អើនៅដើម។ ម៉ាស៊ីននេះមានកង់បីដែលប្រើគល់ឈើជាជំនួយ។ Ali and Akyurt (1998) បានបង្ហាញការរចនាជាច្រើននូវប្រព័ន្ធម៉ាស៊ីនដែលអាចអោយគេធ្វើប្រតិបត្តិការ

ទាក់ទងនិងដំណើរការបេះលម្អើ។ Sclater and Chironis (2001) បានរចនាស្ពឹមុខបីសម្រាប់រ៉ូបូតស្ពឹ។ ពួកគេបានណែនាំយន្តការកម្រិតម៉ាស៊ីនដែលបើកនិងបិទដៃដង្កៀបស្ពឹរ៉ូបូត ហើយអនុញ្ញាតអោយវាចាប់ឬបញ្ចេញវត្ថុ។

## ១០.ការស្តុកទុក (ប្រតិបត្តការប្រមូលផលនិងក្រោយពេលប្រមូលផង)

នៅដំណាក់កាលដើមលម្អើពេញវ័យ ដែលនាំអោយការប្រមូលយកផលនៃផ្លែវាខុសប្លែកគ្នានោះគឺអាស្រ័យទៅលើលក្ខខណ្ឌអាកាសធាតុ ចំណង់ចំណូលចិត្តរបស់អ្នកប្រើប្រាស់ ប្រភេទគ្រាប់ដែលបានបណ្តុះបច្ចេកទេសកែច្នៃ និងវិធីសាស្រ្តជ្រើសរើស។ លើសពីនេះទៅទៀតមិនមែនគ្រប់ទាំងផ្កាញីទាំងអស់ផលិតផ្កានៅពេលដំណាលគ្នាទេ។ ដំណាក់កាលទុំនៃលម្អើក៏វាមានការទុំតៗគ្នាក្នុងមែកផ្សេងៗគ្នាផងដែរ។ នៅក្នុងអេហ្ស៊ីប ដំណាក់កាល Khalal, Rutab,and Tamar របស់លម្អើត្រូវបានគេប្រមូលផលនៅក្នុងចង្កោមទាំងមូលតែម្តង ពេលដែលផ្លែលម្អើភាគច្រើនទុំ។ ពូជដូចគ្នាប្រហែលជាមានការប្រមូលជាបន្តបន្ទាប់គ្នាចាប់ពី ៣ ទៅ ៤ សប្តាហ៍។ ក្នុងករណីភាគច្រើនកម្មករបានឡើងទៅដើមលម្អើ ដើម្បីទៅអោយដល់ចង្កោមមែកដោយប្រើបច្ចេកទេសជាច្រើនដើម្បីឡើងទៅអោយដល់ចុង។ អ្នកឡើងភាគច្រើនឡើងដោយជើងទទេរហើយប្រខ្សែរពួរភ្ជាប់ទៅនឹងខ្សែរធំទូលាយមួយ។ នៅអេហ្ស៊ីបមិនមានម៉ាស៊ីនជាជំនួយដល់អ្នកប្រមូលផលទេ ប៉ុន្តែគ្រាន់តែគេប្រើជណ្តើរឈើជាជំនួយដែលអនុញ្ញាត្តិអោយកម្មករឆាប់ទៅដល់ផ្លែបានឆាប់ជាងមុនកាត់បន្ថយភាពអស់កម្លាំងនិងហានិភ័យនៃការរងរបួស។ កម្មករបានកាត់ចង្កោមនៃលម្អើហើយដាក់ពួកវានៅលើកន្ទេលដែលក្រាលនៅដី ហើយផ្លែដែលបានយកចេញពីចង្កោមទាំនោះត្រូវបានគេរុំយ៉ាងប្រុងប្រយ័ត្នបន្ទាប់ទើបដឹងទៅផ្ទះធ្វើការវេចខ្ចប់វិញ។ ជនជាតិអេហ្ស៊ីបគេប្រើប្រាស់ផ្លែលម្អើនៅដំណាក់កាល(Khalal and Rutab) ដំណាក់កាលនេះមានតែក្នុងអំឡុងពេលប្រមូលផលប៉ុណ្ណោះ ខណៈលម្អើស្ងួតត្រូវបានគេរក្សាទុកក្នុងប្រអប់វេចខ្ចប់តាមប្រពៃណីដែលត្រូវបានគេប្រើប្រាស់ពេញមួយឆ្នាំ ឬនាំចេញទៅលក់។

នៅក្នុងប្រទេសអេហ្ស៊ីបលម្អើស្រស់ជាធម្មតាត្រូវបានគេលាងសម្អាត បន្ទាប់មកត្រូវបានគេបំបែកទៅជាប្រភេទផ្សេងៗដោយយោងទៅតាមវាយណភាព កម្រិតសំណើម និងរូបរាង។ ផ្លែដែលទុំជ្រុលត្រូវបានគេដកយកចេញ ក៏ដូចជាផ្លែដែលខូចឬតូចពេក។ បន្ទាប់មកលម្អើត្រូវបានគេយកគ្រាប់ចេញមុនពេលគេយកទៅវេចខ្ចប់អាស្រ័យទៅទីផ្សារដែលបានគ្រោងទុក។ យោងទៅតាមលទ្ធផលស្រាវជ្រាវ ការទុកដាក់ក្រោយពេលប្រមូលផល មានតួនាទីយ៉ាងសំខាន់ក្នុងការកែលម្អគុណភាពផ្លែទាំងអំឡុងពេលស្តុកទុកនៅកន្លែងត្រជាក់និងអំឡុងពេលយកទៅលក់នៅទីផ្សារ។ សីតុណ្ហភាពដែលល្អបំផុតក្នុងការរក្សាទុកផ្លែលម្អើគឺចាប់ពី 0 ទៅ ៤

អង្សាសេ និងការប្រែប្រួលសំណើមពី ៨៥ ទៅ ៩០% ដែលត្រូវបានគេរក្សាទុកក្នុងរយៈពេលមួយខែឬច្រើនខែ អាស្រ័យទៅលើប្រភេទពូជ (Al-Redhaiman, 2005)។ ការសិក្សាថ្មីៗនេះគឺអនុវត្តនៅលើពូជ Zaghloul, Samany, Amhat, and Siwy cvs. ដើម្បីស្រាវជ្រាវពីប្រសិទ្ធភាពនៃការប្រើទឹកក្តៅហើយនិង សូដ្យូមកាបូណាត ជាជម្រើសក្នុងការប្រើសារធាតុគីមីទាំងនេះដើម្បីគ្រប់គ្រងការបំផ្លាញក្រោយពេលប្រមូលផលនៅអំឡុងពេល រក្សាទុកនៅកន្លែងត្រជាក់(Hafez et al. 2012 )។ ជាលទ្ធផលដែលទទួលបាន បានបង្ហាញអោយដឹងថាដែល យើងស្តុកទុកនៅកន្លែងត្រជាក់ បានការពារនូវប្រព្រឹត្តកម្មភ្នាក់ងារបង្ករជំងឺផ្សិតរហូតដល់ទៅ៤0ថ្ងៃ ទាំងផ្លែ ដែលមានការព្យាបាលនិងមិនការព្យាបាល។ ប្រព្រឹត្តកម្មទឹកក្តៅនិងសូដ្យូមកាបូណាតគឺបន្ថែមប្រសិទ្ធភាព ជាងមុនទៅបន្ថយការបាត់បង់ទំងន់(%)ហើយនិងការស្អុយផ្លែ(%) បើប្រៀបធៀបជាមួយនិងការដែលមិនបាន ព្យាបាលផ្លែ គេបានស្រាវជ្រាវបែបនេះគ្រប់ពូជទាំងអស់។ ការព្យាបាលទាំងនេះផងដែរបានពន្យាផ្លែកុំ អោយ ខូចរហូតដល់ទៅ២0ថ្ងៃដោយការរក្សាទុកនៅកន្លែងត្រជាក់នៅAmhat និង Siwy cvs។ បើមិនដូច្នេះទេក្នុងការ សិក្សាស្តីពីការរក្សាទុកនៃ Siwy cv., Nazam El-Din and Abd El-Hameed ( 2001) បានរាយការណ៍ថាក្នុង ព្យាបាលលម្មើជាមួយ ស៊ុលហ្វាតឌីអុកស៊ីត(sulfate dioxide) នាំអោយមានពណ៌ល្អបំផុតនិង ហើយនិង ពណ៌ដែលមិនអាចទទួលបានលេចចេញនៅក្នុងប្រអប់ផ្លាស្ទិចដែលគេបានវេចខ្ចប់។ ជាមួយការយកចិត្ត ទុកដាក់ទៅលើការវេចខ្ចប់តាមប្រភេទផ្សេងៗគ្នាត្រូវបានគេប្រើទាំងប្លាស្ទិច កេសក្រដាស និងកេសឈើ។ ជា ធម្មតាលម្មើត្រូវបានគេខ្ចប់នៅក្នុងប្រអប់ការតុងដែលចំហផ្នែកខាងលើចាប់ពី ១,៣ ឬ ៥ គីឡូក្រាមយោងទៅ តាមតម្រូវការអ្នកទិញ(លម្មើស្រស់) ក្រដាសកាតុង ៥ ឬ ១០ គីឡូក្រាម (លម្មើស្ងួតពាក់កណ្តាលស្រស់ពាក់ កណ្តាល) និងក្រដាសកាតុង ១០ ឬ ២៥ គីឡូក្រាម(លម្មើស្ងួត)។ ថ្វីបើមានសារៈសំខាន់និងតំបន់វប្បកម្មទូលំ ទូលាយនៃការដាំដុះដំណាំលម្មើតាមប្រពៃណីនិយមក៏ដោយ ក៏ចម្ការក្រោយពេលប្រមូលផលមានការខាតបង់ ខ្ពស់ និងវិធីសាស្រ្តចំពោះការវាស់វែងគុណភាពផលិតផលនិងការប្រើផលិតផលលម្មើហើយនិងផលិតផល ចាំបាច់ត្រូវបានកែលម្អ។

## ១១.ការកែច្នៃ (Processing)

លម្មើគឺជាដំណាំពាណិជ្ជកម្មដ៏សំខាន់មួយ ដែលតូវបានដាំដុះនៅក្នុងតំបន់ផ្សេងៗ ក្នុងពិភពលោក។ ផ្លែលម្មើត្រូវបានគេនិយមចូលចិត្តដោយសារវាមានរសជាតិផ្អែមឆ្ងាញ់ មានឱជារសល្អ និងមានរសជាតិប្លែក។ ផ្លែរបស់វាត្រូវបានគេកែច្នៃទៅជាផលិតផលជាច្រើនប្រភេទ។ ផលិតផលដែលផលិតចេញមកពីលម្មើរួមមាន លម្មើស្ងួត ត្រៀបលម្មើ(Date Bars) ទឹកស៊ីរ៉ូលម្មើ(Date syrup) ទឹកផ្លែខាប់(Date juice concentrate) ដំណាប់លម្មើ(Date jam) ប៊ឺរលម្មើ(Date butter) ស្ករគ្រាប់លម្មើ(Date candy) ទឹកជ្រលក់លម្មើ(Date chutney) គ្រឿងបន្ថែមរសជាតិ(Date relish) ទឹកជ្រក់លម្មើ(Date pickles) ស្រាលម្មើ(Date wine) ។ល។ ប្រេងលម្មើនិងកាហ្វេលម្មើគឺជាផលិតផលមួយចំនួនដែលផលិតចេញមកពីគ្រាប់លម្មើ។



# ១២.ឯកសារយោង


១. សៀវភៅ Organic Farming in the Tropics and subtropics (Date Palm),Insect

២. សៀវភៅ Dates (Production, Processing Food, and Medicinal Values) – 1 An overview of Date Palm Production (Botanical Description of Date Palm) - Processing of Dates into Value-Added Products ,P. Vijayanand and S. G. Kulkarni

៣. https://www.wikihow.com/Plant-Date-Seeds

៤. https://www.health.com.kh/archives/31078

៥. https://fdc.nal.usda.gov/fdc-app.html#/food-details/171726/nutrients

៦. https://www.frontiersin.org/articles/10.3389/fpls.2017.00845/full

៧. https://www.feedipedia.org/node/687

៨. http://www.fao.org/3/Y4360E/y4360e05.htm (Root system & Seed)

៩. សៀវភៅ Climate Change, Food Security and Natural Resource Management (9.3 A Case Study of Date Palm Water Requirement)

១០. សៀវភៅ Organic Fruit and Vegetables from the Tropics – 2.9.6. Diversification strategies